ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខ: ២៥០ សាហក

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី ស្ថានភាពពលរដ្ឋភៀសសឹក និងផលប៉ះពាល់លើតំបន់ស៊ីវិលកម្ពុជា
# គិតមកត្រឹមព្រឹកថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៦

ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា សូមជម្រាបជូនសាធារណមតិជាតិ និងអន្តរជាតិជ្រាបថា ចាប់តាំងពីបទឈប់បាញ់រវាងកម្ពុជា និងថៃ បានចូលជាធរមាន កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ផ្អែកតាមសេចក្តីប្រកាសរួមនៃកិច្ចប្រជុំពិសេសលើកទី៣ របស់គណៈកម្មាធិការព្រំដែនទូទៅ (GBC) ភាគីថៃពុំបានអនុវត្តតាមកាតព្វកិច្ចបទឈប់បាញ់នេះឱ្យបានពេញលេញ និងស្មោះត្រង់ឡើយ។ ផ្ទុយទៅវិញ យោធាថៃបាននិងកំពុងបន្តរំលោភយ៉ាងធ្ងន់ធ្ងរលើអធិបតេយ្យភាព និងបូរណភាពទឹកដីកម្ពុជា តាមរយៈការកាន់កាប់ទីតាំងស៊ីវិល ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិពលរដ្ឋស៊ីវិល និងការរារាំងប្រជាពលរដ្ឋកម្ពុជាមិនឱ្យវិលត្រឡប់ទៅកាន់លំនៅឋានដើមវិញ។

ក្រសួងមហាផ្ទៃ សូមធ្វើបច្ចុប្បន្នភាពទិន្នន័យបឋម គិតត្រឹមព្រឹកថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៦ ដូចខាងក្រោម៖

**១- ស្ថានភាពជនភៀសសឹក និងការរំលោភលើច្បាប់មនុស្សធម៌អន្តរជាតិ៖** ក្នុងចំណោមជនភៀសសឹកសរុបជាង៦៤០.០០០នាក់ នៅមានប្រជាពលរដ្ឋចំនួន១៨.៧០៣នាក់ទៀត (ក្នុងនោះមានស្ត្រី៩.៤៣៧នាក់ និងកុមារ ៦.០៦៦ នាក់) មិនទាន់អាចវិលត្រឡប់ទៅកាន់ភូមិករណ៍ និងលំនៅឋានដើមវិញ ដោយសារការរារាំងពីសំណាក់យោធាថៃ។ ការរារាំង និងការមិនអាចវិលត្រឡប់នេះ មិនមែនជាផលប៉ះពាល់ដោយអចេតនានៃជម្លោះនោះទេ ប៉ុន្តែជាលទ្ធផលផ្ទាល់នៃការបន្តកាន់កាប់ដោយខុសច្បាប់ពីសំណាក់យោធាថៃមកលើភូមិឋានស៊ីវិល និងការចូលកម្ទេចផ្ទះសំបែង ទ្រព្យសម្បត្តិពលរដ្ឋ បន្ទាប់ពីបទឈប់បាញ់បានចូលជាធរមាន។ សកម្មភាពទាំងនេះ ក៏បានរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ដែលបានហាមឃាត់ដាច់ខាតការបណ្តេញចេញ ការផ្ទេរដោយបង្ខំ និងការជម្លៀសជនស៊ីវិលពីទឹកដីដែលត្រូវកាន់កាប់។

**២- ការខូចខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផ្អាកសេវាសាធារណៈជាមូលដ្ឋាន៖** អំពើឈ្លានពាន និងការបន្តកាន់កាប់ដោយខុសច្បាប់របស់ភាគីថៃ បានបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិសាធារណៈ និងឯកជន ព្រមទាំងបេតិកភណ្ឌវប្បធម៌កម្ពុជា។ ក្នុងនោះ ទ្រព្យសម្បត្តិឯកជន ខូចខាតជាបឋម រួមមាន ផ្ទះ១.៥៥៨ខ្នង អគារស៊ីវិល៧ សណ្ឋាគារ/អគារស្នាក់នៅ១០ ស្ថានីយប្រេង៤ ផ្សារឯកជន១ រថយន្ត៣៤គ្រឿង ម៉ូតូ១០គ្រឿង លានទិញដំឡូង១ ឃ្លាំងទំនិញ១ បង្គោលអង់តែនទូរស័ព្ទ៣៩ និងប្រព័ន្ធទឹកស្អាត៦កន្លែង ដែលជាការរំលោភទាំងស្រុងលើសិទ្ធិម្ចាស់កម្មសិទ្ធិ និងសិទ្ធិរស់នៅដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) ឆ្នាំ១៩៤៨។ ជាមួយគ្នានេះ ទ្រព្យសម្បត្តិសាធារណៈ ខូចខាតជាបឋម រួមមាន សាលារៀន២៦ មន្ទីរពេទ្យ/មណ្ឌលសុខភាព១៤ អគាររដ្ឋបាល៧៤ វត្តអារាម១៩ សាលាឆទាន១ រូបសំណាក២ រថយន្ត១គ្រឿង ស្ពាន៥ ផ្លូវ៨៧ខ្សែ ផ្សារ១ បណ្តាញបញ្ជូនអគ្គិសនី៣កន្លែង និងប្រាសាទបុរាណចំនួន៤កន្លែង ដែលជាការរំលោភទាំងស្រុងលើអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤ ស្តីពីការការពារសម្បត្តិវប្បធម៌ និងបេតិកភណ្ឌពិភពលោក។ បន្ថែមលើនេះ ការបន្តបិទទ្វារសាលារៀនសរុប១៥កន្លែង និងមណ្ឌលសុខភាព/មន្ទីរពេទ្យ៧កន្លែង ក្នុងខេត្តឧត្តរមានជ័យ បន្ទាយមានជ័យ និងព្រះវិហារ បានធ្វើឱ្យកុមារ និងប្រជាពលរដ្ឋបាត់បង់សិទ្ធិទទួលបានការសិក្សា និងសេវាថែទាំសុខភាពជាមូលដ្ឋាន។

ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា គាំទ្រការតវ៉ារបស់រាជរដ្ឋាភិបាលជាផ្លូវការចំពោះការបន្តរំលោភបំពានដោយប្រទេសថៃមកលើអធិបតេយ្យ និងបូរណភាពទឹកដីរបស់កម្ពុជា តាមបណ្តោយព្រំដែន។ ជាក់ស្តែងកាលពីថ្ងៃទី២៦ ខែកក្កដា ដល់ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៦ នៅសង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តបន្ទាយមានជ័យ កងកម្លាំងប្រដាប់អាវុធថៃបានបន្តឈូសឆាយព្រៃជាបន្តបន្ទាប់ ដើម្បីសាងសង់ផ្លូវថ្មីមួយខ្សែ ដែលតភ្ជាប់ពីភាគខាងជើងនៃបង្គោលព្រំដែនលេខ១៤ ទៅកាន់តំបន់ភ្នំតាថុង (ភ្នំ២៧៨)។ បន្ទាប់មក នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៦ កងកម្លាំងប្រដាប់អាវុធថៃក៏បានបន្តសកម្មភាពសាងសង់ផ្លូវក្នុងតំបន់ខាងលើ ព្រមទាំងបានសាងសង់លេណដ្ឋានយោធាថ្មីផងដែរ។ ជាងនេះទៀត នៅថ្ងៃទី២០ ខែសីហាដដែល កងកម្លាំងប្រដាប់អាវុធថៃបានសាងសង់លេណដ្ឋានយោធាថ្មីមួយចំនួន នៅភាគខាងជើងវត្តកែវសិក្ខាគិរីស្វារៈ ស្ថិតនៅឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ សកម្មភាពនេះ គឺជាការរំលោភបំពានយ៉ាងជាក់ច្បាស់លើអធិបតេយ្យ និងបូរណភាពទឹកដីកម្ពុជា អនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ ស្តីពីការវាស់វែង និងកំណត់ខណ្ឌសីមាព្រំដែនគោក ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០០ និងសេចក្តីប្រកាសរួមនៃកិច្ចប្រជុំពិសេសលើកទី៣ របស់គណៈកម្មការព្រំដែនទូទៅ (GBC) កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ដែលភាគីទាំងពីរបានឯកភាពប្រគល់ជូនគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោក (JBC) ដើម្បីបន្តការងារវាស់វែង និងបោះបង្គោលព្រំដែនឱ្យបានឆាប់បំផុត ស្របតាមកិច្ចព្រមព្រៀងដែលមានស្រាប់រវាងប្រទេសទាំងពីរ។

ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា សូមសង្កត់ធ្ងន់ថា ផ្អែកតាមគោលការណ៍ច្បាប់អន្តរជាតិ **«ដរាបណា អ្នកដែលកំពុងកាន់កាប់ខុសច្បាប់ ត្រូវបានតវ៉ាប្រឆាំងជានិច្ចដោយម្ចាស់ទឹកដី ដរាបនោះអ្នកដែលកំពុងកាន់កាប់ដោយខុសច្បាប់ នឹងមិនទទួលបានសិទ្ធិកាន់កាប់ស្ថាពរឡើយ។ ផ្ទុយទៅវិញ ដរាបណាម្ចាស់ទឹកដីនៅតែប្រឆាំងតវ៉ាជានិច្ច ដរាបនោះ ខ្លួនមិនបាត់បង់សិទ្ធិដោយការផុតអាជ្ញាយុកាលឡើយ»**។ កម្ពុជា ប្រកាសមិនទទួលស្គាល់ជាដាច់ខាតនូវការកែប្រែខ្សែព្រំដែនដោយឯកតោភាគី ឬដោយប្រើប្រាស់កម្លាំង ទាំងពេលកន្លងមក ទាំងបច្ចុប្បន្ន និងអនាគត។

ថ្ងៃចន្ទ ១១កើត ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៦